ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៧៦០ ព.ណ...ឥ.ត.ក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ភ្នំពេញ, ថ្ងៃទី២៩ ខែ កញ្ញា ឆ្នាំ ២០០៩

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការជ្រើសរើសមជ្ឈត្តករដំបូងដើម្បីបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

- ផ្អែកតាមអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

## គណៈកម្មការរៀបចំ និងជ្រើសរើសមជ្ឈត្តករដំបូង

សូមជូនដំណឹងដល់សាធារណជនទាំងពីរភេទដែលមានសញ្ជាតិខ្មែរ ឬបរទេស ឱ្យបានជ្រាបថា: ក្រសួងពាណិជ្ជកម្មនឹងរៀបចំបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយធ្វើការជ្រើសរើសមជ្ឈត្តករដំបូងចំនួនពី ៥០ (ហាសិប)ទៅ ៦០ (ហុកសិប)នាក់។ អាស្រ័យហេតុនេះ សូមអញ្ជើញសាធារណជន សញ្ជាតិខ្មែរ ឬបរទេស ដែលមានបំណងចង់ចុះឈ្មោះធ្វើជាមជ្ឈត្តករផ្នែកពាណិជ្ជកម្មនៅក្នុងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម មកដាក់ពាក្យស្នើសុំនៅលេខាធិការដ្ឋានគណៈកម្មការជ្រើសរើសមជ្ឈត្តករដំបូងដែលមានទីតាំងនៅនាយកដ្ឋាននីតិកម្មនៃក្រសួងពាណិជ្ជកម្ម។

### ១. លក្ខខណ្ឌនៃការដាក់ពាក្យសុំ

ក) បេក្ខជនដែលមានសញ្ជាតិខ្មែរ ឬបរទេសត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម:

- មានអាយុចាប់ពី ៣០ (សាមសិប)ឆ្នាំឡើង
- មានសញ្ញាបត្របរិញ្ញាបត្រជំនាញណាមួយ ក្រោយពីបានបញ្ចប់ការសិក្សានៅតាមសាកលវិទ្យាល័យក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស និង
- មានបទពិសោធន៍ការងារយ៉ាងតិច ៣ ឆ្នាំ។

ប្រសិនបើពុំមានលក្ខណៈសម្បត្តិដូចខាងលើទេ បេក្ខជនដែលមានសញ្ជាតិខ្មែរ ឬបរទេស ត្រូវជាបុគ្គលដែលធ្លាប់ធ្វើជា:

- សមាជិកនៃស្ថាប័នវិជ្ជាជីវៈមជ្ឈត្តការផ្នែកពាណិជ្ជកម្មដែលទទួលស្គាល់ដោយគណៈកម្មការ ឬ
- មជ្ឈត្តករ ឬអ្នកតំណាងក្នុងដំណើរការមជ្ឈត្តការផ្នែកពាណិជ្ជកម្មចាប់ពី៣ដងឡើងទៅ ឬបានសរសេរសេចក្តីបង្គាប់មជ្ឈត្តការផ្នែកពាណិជ្ជកម្មចំនួនយ៉ាងតិច ៣ ក្នុងពេលដែលខ្លួនធ្វើជាមជ្ឈត្តករ ។

ខ) មជ្ឈត្តករមិនត្រូវស្ថិតនៅក្រោមឋានានុក្រមជាមន្ត្រីនៃស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិប្បញ្ញត្តិ និងតុលាការ និងមិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋណាមួយឡើយ ។

គ) បេក្ខជនដែលត្រូវបានជ្រើសរើសដំបូងមិនតិចជាង ៥០ (ហាសិប)រូប ត្រូវដាក់ពាក្យសុំធ្វើជាមជ្ឈត្តករនៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ក្រោយពីបានបញ្ចប់វគ្គបណ្តុះបណ្តាលមជ្ឈត្តការផ្នែកពាណិជ្ជកម្មដែលនឹងរៀបចំដោយគណៈកម្មការ ។

## ២. កាលបរិច្ឆេទទទួលពាក្យ និងទីកន្លែងទទួលពាក្យស្នើសុំ

ការទទួលពាក្យស្នើសុំនឹងប្រព្រឹត្តទៅរៀងរាល់ម៉ោងធ្វើការ នៅនាយកដ្ឋាននីតិកម្មនៃក្រសួងពាណិជ្ជកម្ម ចាប់ពីថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០០៩ រហូតដល់ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៩ វេលាម៉ោង ១៧:០០នាទី ជាកាលបរិច្ឆេទចុងក្រោយនៃការទទួលពាក្យ ។

គណៈកម្មការនឹងឈប់ទទួលពាក្យស្នើសុំមុនកាលបរិច្ឆេទចុងក្រោយ នៅពេលដែលគណៈកម្មការទទួលបានពាក្យស្នើសុំគ្រប់ចំនួន ៦០ (ហុកសិប)នាក់ ។

ចំពោះពាក្យស្នើសុំ និងពតិមានផ្សេងៗទៀត សូមទាក់ទងដោយផ្ទាល់នៅលេខាធិការដ្ឋាននៃគណៈកម្មការជ្រើសរើសមជ្ឈត្តករដំបូងរាល់ម៉ោងធ្វើការ ឬតាមរយៈគេហទំព័ររបស់ក្រសួងពាណិជ្ជកម្មដែលមានអាសយដ្ឋាន www.moc.gov.kh ។

**ជ.ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**
**ប្រធានគណៈកម្មការរៀបចំ និងជ្រើសរើសមជ្ឈត្តករដំបូង**

ម៉ៅ ថូរ៉ា